ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ:......០៦៦/១៩ គ.ជ.ក

# របាយការណ៍បូកសរុប

## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែវិច្ឆិកា និងទិសដៅខែធ្នូ ឆ្នាំ២០១៨

## I. ស្ថានភាពទូទៅ

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីរាជរដ្ឋាភិបាលថៃបានចេញគោលការណ៍រឹតបន្តឹងពលករទេសន្តរប្រវេសន៍ធ្វើការខុសច្បាប់ក្នុងប្រទេសថៃ ចាប់ពីដើមខែកក្កដា ឆ្នាំ២០១៨មក និងទោះបីរាជរដ្ឋាភិបាលកម្ពុជា ក្នុងរយៈពេល៤ឆ្នាំកន្លងទៅនេះ បានផ្តល់ភាពស្របច្បាប់ដល់ពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល។

ពលរដ្ឋខ្មែរនៅតែបាននិងកំពុងចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានីភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌពីអាជ្ញាធរប្រទេសថៃ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស និងពេលវេលាជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួននៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ចផ្តល់ឯកសារក្លែងក្លាយ ជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត· មន្ទីរ អង្គភាព និងដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

ការអនុវត្តយុទ្ធសាស្ត្រ នៃផែនការសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ក.១. សេចក្តីព្រាងច្បាប់ដែលកំពុងរៀបចំ៖

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA)
  - ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

ក.២. សន្ធិសញ្ញាកំពុងរៀបចំ៖

- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ទ្វេភាគី៖
  - **ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"**
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង។
  - **ស្តីពី "បញ្ជូនទណ្ឌិត"**
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលអង់គ្លេស
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

ក.៣. អនុស្សរណៈកំពុងរៀបចំ៖

- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រី លើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្តីពី "**ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី**" នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

ក.៤. បទដ្ឋានគតិយុត្តិ កំពុងរៀបចំ៖

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តល័ក្ខខ័ណ្ឌ ការងារកម្មករការងារផ្ទះ**"។
- **ក្រសួងអប់រំ យុវជន និងកីឡា៖** ធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**"។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. កាត់បន្ថយភាពងាយរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ

រដ្ឋបាលខេត្តចំនួន៣ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែនថៃ បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ សរុបចំនួន **៩.៥៥១**ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មាន:

- ខេត្តបាត់ដំបង ចំនួន ៦.៣១៨ប័ណ្ណ
- ខេត្តបន្ទាយមានជ័យ ចំនួន ២.៨៣០ប័ណ្ណ
- ខេត្តប៉ៃលិន ចំនួន ៤០៣ប័ណ្ណ។

### ខ.២. ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

នៅខែវិច្ឆិកា ឆ្នាំ២០១៨នេះ **ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ** មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចសហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោបាយ **"ភូមិ-ឃុំ មានសុវត្ថិភាព"** ដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន **៤.៧១៨**លើក មានអ្នកចូលរួមសរុបចំនួន **៣៥៤.០៦៧**នាក់(បើប្រៀបធៀបនឹងខែតុលា មានចំនួន **៣១៨.៨៣៧**នាក់) មានការកើនឡើងចំនួន ៣៥.២៣០នាក់ ស្មើនឹង**១១,០៤%** ក្នុងនោះស្ត្រីមានចំនួន **១៩៣.៣៨០**នាក់។ (**ឧបសម្ព័ន្ធទី១**)

### ខ.៣. ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

- **ថ្នាក់ជាតិ៖**
  ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួមជាវាគ្មិននៅវិទ្យុVOD ស្តីពីចំណាកស្រុក និងអំពើជួញដូរមនុស្ស។
- **ថ្នាក់រាជធានី ខេត្ត៖**
  បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធ នឹងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមប៉ុស្តិ៍វិទ្យុ សរុបចំនួន **៤៥**លើក ក្នុងនោះខេត្ត៖
  - ខេត្តកោះកុង ចំនួន ៣០លើក
  - ខេត្តកំពត ចំនួន ០១លើក
  - ខេត្តសៀមរាប ចំនួន ១២លើក
  - ខេត្តក្រចេះ ចំនួន ០២លើក។
- **អង្គការដៃគូ៖**
  អង្គការ សាម៉ារីតាន់ភឺស បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយអប់រំ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករចំណាកស្រុកចំនួន **៧៨**នាក់ (ស្រី **៣៥**នាក់) ដែលបញ្ជូនត្រឡប់ពីព្រំដែន តាមច្រកដូង ខេត្តបាត់ដំបង។

### ខ.៤. វិធានការបង្ការ ទប់ស្កាត់ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ

#### ខ.៤.១. វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖

សាលាខេត្ត នគរបាលជំនាញ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត មន្ទីរចំណុះខេត្ត បានសហការជាមួយ ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការ ទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត៖**

- **កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្តៈ** តាកែវ ស្វាយរៀង មណ្ឌលគិរី កណ្តាល រតនគិរី និងស្ទឹងត្រែង បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើស សញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន **៦៨៦**គោលដៅ មានមនុស្សចំនួន **១៨.៨៣៧**នាក់ (ស្រី **១២.១៦២**នាក់)។
- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន **០៩**គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន **៦៦**គោលដៅ សរុបចំនួន **៧៥**គោលដៅ ទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន **៤១**លើក ខេត្តអនុវត្តមានៈ ស្វាយរៀង ព្រះវិហារ ក្រចេះ ឧត្តរមានជ័យ ស្ទឹងត្រែង និងព្រៃវែង។
- ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖ កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈសេនាតូចការពារព្រំដែនគោកលេខ ៨១៧, ៨១៩, ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែន **៥២**លើក។

- **អង្គការដៃគូ៖**

- **អង្គការម្លប់តាប៉ាង ខេត្តព្រះសីហនុ** ដើម្បីការពារសុវត្ថិភាព កុមារ បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បីចំនួន **១៤៣**នាក់ ផ្ទះសំណាក់ សណ្ឋាគារ **២៤**កន្លែង អ្នកលក់តាមឆ្នេរសមុទ្រ **៧១**នាក់ បណ្តាញតាមសហគមន៍ **៦០**នាក់ ផ្នែកភ្នាក់ងារទេសចរណ៍ **០២**នាក់ សមាជិកបណ្តាញដែលជាបុគ្គលិកផ្ទះសំណាក់/សណ្ឋាគារ **៣៧៤**នាក់។

## ខ.៥. <u>វិធានការប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់</u>

### ខ.៥.១. <u>វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក</u>

- ការធ្វើបច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន **៣៧០.១៧០**នាក់ (ស្រី **១៦០.២១១**នាក់) អនីតិជន **៩.៣៨៦**នាក់ (ស្រី **៣.៥១១**នាក់) ក្នុងនោះស្របច្បាប់ចំនួន**២០៨.៣២៩**នាក់ (ស្រី **៩៣.៨០៩**នាក់) អនីតិជន **៦៥៣**នាក់ (ស្រី **២៧៧**នាក់) មិនស្របច្បាប់ចំនួន **១៦១.៨៤១**នាក់ (ស្រី **៦៦.៤០២**នាក់) អនីតិជន **៨.៧៣៣**នាក់ (ស្រី **៣.២៣៤**នាក់) បើប្រៀបធៀបនឹងខែមុន មានការកើនឡើង ចំនួន **៩.០១៩**នាក់ ស្មើនឹង **២,៤៩%**។

## ខ.៦. <u>ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈ ការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស</u>

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន **១៣៨**គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ចំនួន **១១**នាក់ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

## គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន **១១/០៧**ករណី (បើប្រៀបធៀបនឹងខែតុលា កើនឡើង ០៤ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **២៥**នាក់(ស្រី **១៥**នាក់)។ សង្គ្រោះជនរងគ្រោះ ចំនួន **១១**នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ **០៧**នាក់ និងអាយុ១៨ឆ្នាំឡើង **០៤**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច **០៣**នាក់ និងប្រគល់ទៅគ្រួសារ **០៨**នាក់)។

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **០៣/០៥ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន **១៧**នាក់ (ស្រី **១៤**នាក់) ។ សង្គ្រោះជនរងគ្រោះចំនួន **០១**នាក់ អាយុ១៨ឆ្នាំ (ប្រគល់ឲ្យទៅគ្រួសារ)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០១ |
| -អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ០២ | ១៦ |
| *សរុប* | *០៣ ករណី* | *១៧នាក់* |

**២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ០៨/០២**ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ០៨នាក់(ស្រី **០១**នាក់)។ សង្គ្រោះជនរងគ្រោះចំនួន **១០**នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ **០៧**នាក់ អាយុ១៨ឆ្នាំឡើង **០៣**នាក់ (ប្រគល់ទៅសង្គមកិច្ច **០៣**នាក់ និងប្រគល់ទៅគ្រួសារ **០៧**នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -សញ្ចារកម្ម | ០១ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ | ០៦ |
| -អំពើអាសប្រទាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ |
| *សរុប* | *០៨ ករណី* | *០៨ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួលជនសង្ស័យរងគ្រោះ

- **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

យោងស្ថិតិ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានបញ្ជូនពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការដៃគូ មានចំនួន ៤៨នាក់ (ស្រី ២០នាក់) ក្នុងនោះមកពី៖

- ប្រទេសថៃ ចំនួន ២៦នាក់
- ប្រទេសចិន ចំនួន ១៦នាក់ (ស្រី ១៦នាក់)
- ប្រទេសវៀតណាម ចំនួន ០៤នាក់ (ស្រី ០២នាក់)
- ប្រទេសម៉ាឡេស៊ី ចំនួន ០១នាក់ (ស្រី ០១នាក់)
- ប្រទេសសិង្ហបុរី ចំនួន ០១នាក់ (ស្រី ០១នាក់)។

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

**អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ១០៦លើក មនុស្សចំនួន ១.៨០២នាក់ (ស្រី ៦០៦នាក់ កុមារ ១៩២នាក់)។ ក្នុងនោះតាម៖

- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ មនុស្សចំនួន ៧១នាក់
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ មនុស្សចំនួន ១.៧២៩នាក់
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម មនុស្សចំនួន ០២នាក់។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានាសរុបចំនួន ៥៥នាក់ (ស្រី ០៨នាក់)។ មានដូចខាងក្រោម ៖

- បានទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន ២៩នាក់ (ស្រី ០៨នាក់) ក្នុងនោះមកពី ប្រទេស៖ ចិន ០៧នាក់ សូម៉ាលី ២១នាក់ ម៉ាឡេស៊ី ០១នាក់ (ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ០៧នាក់ និងជួញដូរកម្លាំងពលកម្ម ២២នាក់)។
- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានទទួលសាវតាជនរងគ្រោះដោយអំពើជួញដូរមនុស្សមុនពេលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ ចំនួន ២៦នាក់ ជាករណីជួញដូរកម្លាំងពលកម្ម។

### ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិម្បទាចំនួន ៨៤នាក់ (ស្រី ៣១នាក់) កុមារ ២៣នាក់ ដូចមានក្នុងតារាងខាងក្រោម៖

- បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០៨នាក់(ស្រី) ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ទៅទទួលសេវាបន្តនៅអង្គការដៃគូដូចជា៖ អង្គការមេត្រីអន្តរជាតិ អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ។
- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានបញ្ជូនជនងាយរងគ្រោះ ដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ ចំនួន ៣៦នាក់ (ស្រី ២៣នាក់) កុមារ ២៣នាក់ ទៅអង្គការតំណក់ទឹក ដើម្បីទទួលសេវាអប់រំក្នុង និងក្រៅប្រព័ន្ធ និងសេវាផ្សេងៗ ទៀតមុនពេលធ្វើសមាហរណកម្មត្រឡប់ទៅផ្ទះវិញ។

ឃ.៣. <u>ការធ្វើសមាហរណកម្មជួយជនរងគ្រោះ និងជនងាយរងគ្រោះ</u>

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានចូលរួមធ្វើសមាហរណកម្មស្ត្រីពពោះជំនួស(អ្នកលួតកូន) ចំនួន ០៤នាក់ ទៅសហគមន៍វិញ។

## <u>របាយការណ៍ពីស្ថានភាព៖</u>

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ**

**ស្នងការដ្ឋាននគរបាលខេត្ត** បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាត់បញ្ជូនត្រឡប់មកកម្ពុជាវិញ បានចំនួន **៩១**លើក មនុស្សចំនួន **២.៣១៩**នាក់ (ស្រី **៨១៨**នាក់) អនីតិជន **៣៤២**នាក់ ក្នុងនោះមាន៖

+ **តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ៖**
  - ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ចំនួន **៧៣**លើក មនុស្សចំនួន **២.១០៨**នាក់ (ស្រី **៧០៣**នាក់) អនីតិជន **២៥០**នាក់។
  - ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ចំនួន **១២**លើក មនុស្សចំនួន **៨៩**នាក់(ស្រី **៣៦**នាក់) អនីតិជន ០៣នាក់។

+ **តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម៖**
  - ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀងចំនួន ០៦លើក មនុស្សចំនួន **១២២**នាក់ (ស្រី **៧៩**នាក់) អនីតិជន **៨៩**នាក់។

## ការគ្រប់គ្រងជនបរទេស៖

**អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានបង្ហាញថាមានជនបរទេសដែលល្មើសច្បាប់ ត្រូវបានរកឃើញដូចខាងក្រោម ៖

១. <u>ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់៖</u> ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញពីព្រះរាជាណាចក្រកម្ពុជា មានចំនួន **៦៩**លើក មនុស្សចំនួន **១៨៤**នាក់ មាន **៣៦**សញ្ជាតិ ត្រូវបានបណ្តេញចេញដោយ ៖
- អគ្គនាយកដ្ឋាន ចំនួន **៣៣**លើក មនុស្សចំនួន **១៣៧**នាក់ មាន **១៧**សញ្ជាតិ។
- បដិសេធមិនឲ្យចូលប្រទេស តាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងក្រុមផ្តល់ទិដ្ឋាការ ចំនួន **៣៦**លើក មនុស្សចំនួន **៤៧**នាក់ មាន **១៩**សញ្ជាតិ។

២. <u>ករណីស្នាក់នៅខុសច្បាប់</u>
- ប្រើប្រាស់ទិដ្ឋាក្លែងក្លាយ ០១លើក មនុស្សចំនួន ០១នាក់ សញ្ជាតិប៉ាគីស្ថាន។
- ប្រើប្រាស់លិខិតឆ្លងដែនក្លែងក្លាយ ០២លើក មនុស្សចំនួន ០៣នាក់ មាន ០២សញ្ជាតិ

- (សេនេហ្កាល ០២នាក់ និងម៉ាឡេស៊ី ០១នាក់)។
- ប្រើប្រាស់លិខិតឆ្លងដែនអស់សុពលភាព ០១លើក មនុស្សចំនួន ០១នាក់ សញ្ជាតិចិន។
- លិខិតឆ្លងដែនមិនប្រក្រតី ០១លើក មនុស្សចំនួន ០១នាក់ សញ្ជាតិចិនតៃវ៉ាន់។

## III. ការលើកកម្ពស់សមត្ថភាព

### ក. ក្នុងប្រទេស

#### ក.១. ការងារបណ្តុះបណ្តាលក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័នអនុវត្ត និងលេខាធិការដ្ឋាន រាជធានី-ខេត្ត បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាលបានចំនួន ០៤វគ្គ មានសិក្ខាកាមចូលរួមចំនួន **១៨៩**នាក់ ក្នុងនោះមានស្ត្រី **៧៦**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិក គ.ខ.ប.ជ ៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គលេខាធិការរង បានចូលរួមជាគ្រូឧទ្ទេសនាម ក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការរំលោភបំពានផ្លូវភេទលើកុមារ ជូនដល់បុគ្គលិកអង្គការ UNICEF នៅទីស្នាក់ការអង្គការ UNICEF រាជធានីភ្នំពេញ។ | ០១ | ១៩ | ០៨ |
| ២ | **ខេត្តសៀមរាប** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅស្រុកអង្គរជុំ។ | ០១ | ៦០ | ០៩ |
| ៣ | ខេត្តកោះកុង លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានបើកវគ្គបណ្តុះបណ្តាលស្តីពីការទប់ស្កាត់អំពើហិង្សា និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព | ០២ | ១១០ | ៥៩ |
| សរុប | | ០៤លើក | ១៨៩នាក់ | ៧៦នាក់ |

#### ក.២. សិក្ខាសាលា

- **ថ្នាក់ជាតិ៖**
  - **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានរៀបចំសិក្ខាសាលា ចំនួន ០២វគ្គ គឺ៖
    - សិក្ខាស្តីពី គោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅស្រុកចម្ការលើ ខេត្តកំពង់ចាម ដែលមានសិក្ខាកាមចូលរួមសរុប **៧០**នាក់ (ស្រី **១៥**នាក់) សមាសភាពមានដូចជាៈ មន្ត្រីថ្នាក់ស្រុក មន្ទីរស.អ.យស្រុក មេឃុំ មេភូមិ មន្ត្រីគ.ក.ន.ក គ្រូបង្រៀន គ្រូពេទ្យ និងប៉ូលិសប៉ុស្តិ៍។
    - សិក្ខាសាលាស្តីពី ពង្រឹងយន្តការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួង ស.អ.យ មានសិក្ខាកាមចូលរួមសរុប **៦៥**នាក់ ស្រី **២៩**នាក់ សមាសភាពចូលរួមជា ក្រុមការងារការពារជនរងគ្រោះនៃ គ.ជ.ប.ជ និងអង្គការដៃគូ។
- **ថ្នាក់ក្រោមជាតិ៖**
  - **ខេត្តកណ្តាល**
    សហការជាមួយអង្គការមូលនិធិហាការអន្តរជាតិ បើកសិក្ខាសាលាលើកកម្ពស់ការយល់ដឹងស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងទប់ស្កាត់អំពើជួញដូរមនុស្ស ០១វគ្គ នៅភូមិព្រែកតាទែន ឃុំស្វាយប្រទាល មានសិក្ខាកាមសរុប ២០០នាក់។

ក.៣. ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៤៥**លើក មានអ្នកចូលរួមសរុប **៥៣៩**នាក់ មានស្រី **២០៧**នាក់ ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន **២៣**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន **០៤**លើក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ **០៥**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន **១៦**លើក។ (ឧបសម្ព័ន្ធទី២)

## **ខ. ក្រៅប្រទេស និងថ្នាក់អន្តរជាតិ**

ខ.១. កិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ជាអន្តរជាតិ

- ថ្នាក់ជាតិ៖
  - អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖
    - លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ែន សិរីលក្ខិណា** បានចូលរួមបណ្តុះបណ្តាលវគ្គខ្លីដោយ JICA នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ស្តីពីការពង្រឹងបណ្តាញការងាររបស់ប្រទេសអាស៊ានលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានការចូលរួមពីប្រទេសក្នុងអាស៊ានចំនួន៨ សិក្ខាកាមសរុបចំនួន **១៣**នាក់។
    - លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ែន សិរីលក្ខិណា** បានចូលរួមកិច្ចប្រជុំនៅ បាលី ស្តីពី៖ "Southeast Asia Conference on Regional Coordination, and Action to Combat Trafficking and Labour Exploration in Fisheries ដែលជម្រុញអោយមានការផ្តល់សច្ចាប័នលើ C.188" និង សិក្ខាសាលាស្តីពី៖ "Promotion of Decent Work for Fishers in Southeast Asia"។
    - លោកប្រធានក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិស្តីទី បានចូលរួម "**វគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងសន្តិសុខមនុស្សជាតិ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក**" នៅកោះជេជូ សាធារណៈរដ្ឋកូរ៉េខាងត្បូង។
  - **អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖**
    - បានចូលរួមក្នុងវគ្គកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់អន្តរជាតិកម្ពុជា-ចិន នៅខេត្ត JaingXi ប្រទេសចិន។
    - បានចូលរួមកិច្ចប្រជុំទ្វេភាគី ស្តីពីការពង្រឹងសម្ព័ន្ធភាពអន្តោប្រវេសន៍ថៃ-កម្ពុជា នៅខេត្តស្រះកែវ ប្រទេសថៃ។

# IV. **ការសន្និដ្ឋានវាយតម្លៃ**

## **ក.ចំណុចខ្លាំង**

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។

- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធ និងបែងចែកការទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬអង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ។

## គ.សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនិមួយៗ ដើម្បីប្រសិទ្ធភាពការងារ។

- ស្នើឲ្យលេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែធ្នូ ឆ្នាំ២០១៨

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងារ របស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ **"គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី"** (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.........ខែ.........ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី.........ខែ.........ឆ្នាំ២០១៩

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈ ខែវិច្ឆិកា ឆ្នាំ២០១៨

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាពដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 117 លើក | 11,722 នាក់ | 9,474 នាក់ |
| 2 | ខេត្តកណ្តាល | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 469 លើក | 41,566 នាក់ | 21,522 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ជ្រាបតាមកិច្ចប្រជុំនានាដល់អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | ក្រុមការងារថ្នាក់ស្រុក និងមន្ទីរអប់រំយុវជន និងកីឡា | 117 លើក | 8,109 នាក់ | 4,038 នាក់ |
| 3 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្តីពីការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 747 លើក | 57,527 នាក់ | 30,818 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | | 341 លើក | 13,966 នាក់ | 7,013 នាក់ |
| 4 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 142 លើក | 4,616 នាក់ | 2,416 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅតាមវិទ្យាល័យ អនុវិទ្យាល័យទាំង២០ ទូទាំងខេត្តពោធិ៍សាត់ សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ។ | ស្នងការដ្ឋាននគរបាលខេត្ត | 361 លើក | 58,093 នាក់ | 30,504 នាក់ |
| 5 | ខេត្តសៀមរាប | ផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | មន្ទីរអប់រំ មន្ទីរកិច្ចការនារី ស្នងការដ្ឋាននគរបាលខេត្ត និងរដ្ឋបាលស្រុក | 23 លើក | 1,443 នាក់ | 800 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 110 លើក | 16,020 នាក់ | 8,891 នាក់ |
| 6 | ខេត្តកំពង់ឆ្នាំង | វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 464 លើក | 19,933 នាក់ | 10,423 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបការយល់ ដឹងតាមរយៈកិច្ចប្រជុំនានា ដល់ប្រជាពលរដ្ឋ កម្មករនិយោជិត និងយុវជន។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំខេត្ត មន្ទីរការងារខេត្ត | 4 លើក | 141 នាក់ | 41 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | ខេត្តកំពង់ឆ្នាំង | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងបញ្ជ្រាប ច្បាប់ស្តីពីការជួញដូរមនុស្ស ដល់ ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 540 លើក | 38,992 នាក់ | 22,086 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ។ | ស្នងការដ្ឋាននគរបាលខេត្ត | 140 លើក | 7,183 នាក់ | 3,700 នាក់ |
| 7 | ខេត្តកំពង់ចាម | ផ្សព្វផ្សាយអំពីនីតិវិធីទៅធ្វើការនៅក្រៅប្រទេសដល់មេឃុំ មេភូមិ ផ្តោតលើសំណុំឯកសារស្របច្បាប់ សម្រាប់ពលករទៅធ្វើការនៅក្រៅប្រទេស អនុក្រឹត្យលេខ ១៩០ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំខេត្ត មន្ទីរការងារខេត្ត | 2 លើក | 81 នាក់ | 32 នាក់ |
| | | ផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | | 500 លើក | 34,505 នាក់ | 21,240 នាក់ |
| 8 | ខេត្តកំពង់ធំ | ផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 9 លើក | 650 នាក់ | 508 នាក់ |
| 9 | ខេត្តព្រះសីហនុ | ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ ស្តីការពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ស្រុក មេបញ្ជាការ មេបញ្ជាការរង អធិការ អធិការរង មេប៉ុស្តិ៍ គ.ក.ន.កឃុំ មេភូមិ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរកិច្ចការនារីខេត្ត | 1 លើក | 38 នាក់ | 9 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទបស្កាតអំពើជួញដូរមនុស្ស និងការធ្វើចណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | ក្រុមការងារគ.ខ.ប.ជខេត្ត និងអាជ្ញាធរក្រុង/ស្រុក | 41 លើក | 2,358 នាក់ | 1,070 នាក់ |
| 10 | ខេត្តព្រះវិហារ | ផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថានខុសច្បាប់ ដល់កងកម្លាំងមន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 7 លើក | 2,332 នាក់ | 769 នាក់ |
| 11 | ខេត្តកំពត | វេទិកាផ្សព្វផ្សាយ ស្តពីការទបស្កាតអំពើជួញដូរមនុស្ស និងការធ្វើចណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | ??? លើក | 2,220 នាក់ | 1,235 នាក់ |
| 12 | ខេត្តកែប | វេទិកាផ្សព្វផ្សាយ ស្តពីការទបស្កាតអំពើជួញដូរមនុស្ស និងការធ្វើចណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 33 លើក | 9,992 លើក | 4,905 លើក |
| 13 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត។ | ក្រុមការងារអធិការនគរបាល ក្រុង ស្រុក | 23 លើក | 756 នាក់ | 371 នាក់ |
| 14 | ខេត្តកំពង់ស្ពឺ | ផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 6 លើក | 1,368 នាក់ | 660 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 15 | ខេត្តស្វាយរៀង | វេទិកាសាធារណៈ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 295 លើក | 11,311 នាក់ | 6,593 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរភូមិ ឃុំ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 15 លើក | 84 នាក់ | 74 នាក់ |
| 16 | ខេត្តតាកែវ | ផ្សព្វផ្សាយស្តីពីការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព និងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរសង្គមកិច្ចខេត្ត | 159 លើក | 6,817 នាក់ | 3,259 នាក់ |
| 17 | ខេត្តក្រចេះ | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរសង្គមកិច្ចខេត្ត | 2 លើក | 104 នាក់ | 63 នាក់ |
| 18 | ខេត្តប៉ៃលិន | វេទិកាសាធារណៈ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 21 លើក | 943 នាក់ | 407 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរសង្គមកិច្ចខេត្ត | 29 លើក | 1,197 នាក់ | 459 នាក់ |

សកម្មភាពសរុបចំនួន: 4,718 លើក

មនុស្សសរុបចំនួន: 354,067 នាក់

ស្រីសរុបចំនួន : 193,380 នាក់

# ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៤៥លើក) មនុស្សចំនួន ៥៣៩នាក់ (ស្រី ២០៧នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | សម្របសម្រួលចំនួន ២៣លើក មនុស្សចំនួន ២៤៥នាក់ (ស្រី ៣៥នាក់)<br>លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាគម្រោងចុះអប់រំ នៅតាមបណ្តារោងចក្រ សហគមន៍ ស្តីពីការបង្ការ ទប់ស្កាត់ អំពើដួលពពោះជំនួស សមាសភាពចូលរួមមាន: អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស តំណាងសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ តំណាងអង្គការ ការីតាសកម្ពុជា តំណាងអង្គការចាប់ដៃ ក្រុមកាយរឹទ្ធិនារី និងអង្គការ AIM សរុបចំនួន ១៩នាក់ ស្រី ០៩នាក់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានដឹកនាំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្នុងជំនួបសំណេះសំណាលសម្តែងការគួរសម ពីសំណាក់តំណាងអង្គការ IJM ប្រចាំសហរដ្ឋអាមេរិក និងពិភាក្សាអំពីភាពជាដៃគូ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុង ស្តីពីរបាយការណ៍រយៈពេល១០ខែ ឆ្នាំ២០១៨ របស់ក្រុមជំនួយកិច្ចការទាំង ៦ អ្នកចូលរួមចំនួន ៣៣នាក់ ស្រី ០៤នាក់។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សា ជាមួយអង្គការក្រៅរដ្ឋាភិបាលជាដៃគូ ស្តីពីការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ អ្នកចូលរួមចំនួន ២២នាក់ ស្រី ០៨នាក់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាបញ្ហាស្ត្រី ៣២នាក់ ជាមួយក្រុមអ្នកច្បាប់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានអញ្ជើញជាអធិបតីភាព ក្នុងកិច្ចប្រជុំបូកសរុបរបាយការណ៍រយៈពេល១០ខែ ឆ្នាំ២០១៨ និងលើកទិសដៅអនុវត្តបន្ត របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួងមហាផ្ទៃ អគារ ទ អ្នកចូលរួមចំនួន ១១៧នាក់។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុង ស្តីពីការរៀបចំទិវាជាតិ ១២ ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ អ្នកចូលរួមចំនួន៤០នាក់ ស្រី ០៦នាក់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានចុះបេសកកម្ម នៅខេត្តបន្ទាយមានជ័យ ដើម្បីចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យ ពិភាក្សាលើក្រុមការងារចម្រុះសម្រាប់ទទួលពលករកម្ពុជា ដែលអាជ្ញាធរថៃបញ្ជូនមកនៅមណ្ឌលសំចតប៉ោយប៉ែត អ្នកចូលរួមចំនួន ៣១នាក់ ស្រី ១០នាក់ មានអន្តរក្រសួង ស្ថាប័ន និងអង្គការការដៃគូ។ |

លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ

- បានដឹកនាំប្រជុំក្រុមជំនួយកិច្ចការជួយជនរងគ្រោះ ដើម្បីពិភាក្សាធ្វើមេរៀនសម្រាប់ចុះបណ្តុះបណ្តាល។
- បានដឹកនាំក្រុមជំនួយកិច្ចការការពារជនរងគ្រោះ ចុះសួរសុខទុក្ខស្ត្រីពពោះជំនួសទាំង ៣២នាក់ នៅមន្ទីរពេទ្យ ១៦ឧសភា នឹងជួបជាមួយមេធាវីការពាក្តីរបស់ពួកគេ ដើម្បីពិនិត្យតាមដាននីតិវិធីក្នុងការជួយឲ្យស្ត្រីទាំងអស់បាននៅក្រៅឃុំ។
- បានប្រជុំពិភាក្សាធ្វើមេរៀនជាមួយក្រុមជំនួយកិច្ចការការពារជនរងគ្រោះ សម្រាប់សហការជាមួយ Child Fund។

១ . ក្រុមជំនួយការបង្ការ ទប់ស្កាត់:

- ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ុន វ៉ូ អគ្គលេខាធិការរង បានចូលរួមពិភាក្សា រៀបចំឯកសារ មេរៀន សម្រាប់ចុះបើកវគ្គបណ្តុះបណ្តាល ដល់មន្ត្រីអាជ្ញាធរមូលដ្ឋានក្នុងខេត្តស្វាយរៀង ដោយមានកិច្ចសហការពីក្រសួងសង្គមកិច្ច និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

២. ក្រុមការងារអនុវត្តច្បាប់

- ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨៖ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គលេខាធិការរង បានចូលរួមសិក្ខាសាលាកម្រិតខ្ពស់ ស្តីពីការពិនិត្យតាមដានប្រាក់ឈ្នួលអប្បបរមា។
- បានចុះស្រាវជ្រាវរកអត្តសញ្ញាណ និងរកទីតាំងសាលាបច្ចេកទេសជួសជុលរថយន្ត និងម៉ូតូគ្រប់ប្រភេទហៅកាត់ AMS (Automo biles and Motorcycles Mechanics School) ដែលបានផ្សព្វផ្សាយតាមទូរទស្សន៍ប៉ុស្តិ៍លេខ៣ ជ្រើសរើសជាងតម្លើងរថយន្តទៅធ្វើការងារនៅប្រទេសជប៉ុន។

៣. ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ

- បានប្រជុំក្រុមការងារការពារជនរងគ្រោះធ្វើសុំណើទៅសម្តេចក្រឡាហោម ស្តីពីការបញ្ជូនស្ត្រីរកស៊ីពពោះទៅមន្ទីរពេទ្យ ១៦ឧសភា រាល់ពេលមានករណីបង្ក្រាប។
- ក្រុមការងារការពារជនរងគ្រោះ នឹងអង្គការ AKP បានចុះទៅពិនិត្យសុខភាពស្ត្រីពពោះជំនួស។
- បានស្រង់ទិន្នន័យពលរដ្ឋខ្មែររងគ្រោះលើទូកនេសាទចំនួន ២៣នាក់ ប្រទេសសុម៉ាលី ដែលអាជ្ញាធរ បរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ។

៤. ក្រុមជំនួយកិច្ចការយុត្តិធម៌:

- បានទំនាកទំនង ក្រសួងយុត្តិធម៌ ដើម្បីសុំរបាយការណ៍ប្រចាំខែ និងត្រីមាសទី៣។

៥. ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ:

- លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា បានអញ្ជើញចូលរួមប្រជុំជាមួយ ឯកឧត្តម ឧត្តមសេនីយ៍ឯក យ៉ែម ច័ន្ទណារ៉ុ ស្តីពីការរៀបចំថ្ងៃ១២ធ្នូ។

- លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន **សិរីលក្ខិណា** បានដឹកនាំក្រុមការងារដើម្បីបើកកិច្ចប្រជុំជាមួយក្រុមការងារបច្ចេកទេសដេតាបេស ដើម្បីពិភាក្សាលើការកែសម្រួល ទម្រង់ និងវិធីសាស្ត្រក្នុងការបញ្ចូលព័ត៌មាន។
- លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន **សិរីលក្ខិណា** លោកនាយការិយាល័យស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យ និងមន្ត្រីក្រុមជំនួយកិច្ចការយុត្តិធម៌ បានចូលរួមសិក្ខាសាលាដែលបានផ្តោតទៅលើខ្លឹមសារបីសំខាន់ៗគឺ ១."ការអភិវឌ្ឍន៍យុទ្ធសាស្ត្រ និងឆ្លើយតបទៅនិងបរិបទនៃការបង្កើតថ្មី ដោយយោងទៅលើបទដ្ឋានដែលព្រមព្រៀងគ្នា ដើម្បីបញ្ចប់ការជួញដូរ និងការរំលោភបំពាន" ២."ពង្រឹងកម្មវិធីចម្រុះដោយការជូនដំណឹងស្តីពី ស្តង់ដារ,ច្បាប់,ម៉ូដែល និងការអនុវត្តដែលល្អបំផុត" ៣."កំណត់ពីនិន្នាការ និងគម្លាតនៃការជួញដូរមនុស្ស ដោយក្បោនៅការស្វែងរក និងស្រាវជ្រាវសមាជិកថ្មី ដែលជាប់ពាក់ព័ន្ធ" សិក្ខាសាលានេះប្រព្រឹត្តិទៅនៅអគារ International Christian Fellowship (CIF) ដែលមានការចូលរួមមកពីស្ថាប័នអង្គការជាតិ និងអន្តរជាតិដែលជាដៃគូរបស់អង្គការសម្ព័នចាប់ដៃប្រហែលជាង ១០០រូប។
- លោកជំទាវ រ៉ែន **សិរីលក្ខិណា** បានដឹកនាំការប្រជុំត្រួតពិនិត្យកម្លាំង និងបានធ្វើបទបង្ហាញ ចែករំលែកបទពិសោធន៍ និងចំណេះដឹងបន្ទាប់ពីលោកជំទាវ បានត្រឡប់មកពីការចូលរួមវគ្គបណ្តុះបណ្តាលខ្លីនៅប្រទេសជប៉ុន។
- លោកប្រធានក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិស្តីទី បានចូលរួមសិក្ខាសាលាមួយស្តីពី៖ ការពង្រឹងកិច្ចអន្តរាគមន៍មុនពេលចេញដំណើរពីកម្ពុជាវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាពិភាក្សាពីដៃគូអ្នកពាក់ព័ន្ធ ដែលប្រព្រឹត្តិទៅនៅ សណ្ឋាគារ សាន់វ៉េ ភ្នំពេញ ដែលត្រូវបានរៀបចំដោយ VERITE។ VERITE គឺជាអង្គការក្រៅរដ្ឋាភិបាលមួយដែលតំណាងឲ្យក្រុមហ៊ុនយក្សចំនួន 500 (Fortune 500) ដើម្បីជួយពួកគេក្នុងការធ្វើសវនកម្ម គោរពតាមបទដ្ឋានដែលស្របតាមស្តង់ដារសង្គម (ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សលើសង្វាក់ផ្គត់ផ្គង់ Supply Chain)។

**៦. ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍:**

- មន្ត្រីក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ចំនួន ០១រូប បានចូលរួមកិច្ចប្រជុំជាមួយក្រុមការងារ IT របស់អគ្គលេខាធិការដ្ឋាន គ ជ ស្តីពីការ.ប.ជ.log in ក្នុង WiKi ការសិក្សានិងការប្រើប្រាស់ WiKi ក្រោមការដឹកនាំរបស់លោកវរសេនីយ៍ឯក **អ៊ិន មាន** អនុប្រធានក្រុមការងារIT នៃអគ្គលេខាធិការដ្ឋាន គជ។.ប.ជ.
- លោកអនុប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី ការពិនិត្យមើលទៅលើវិធីសាស្ត្រការស្រាវជ្រាវចំពោះផលប៉ះពាល់ នៃអំពើជួញដូរមនុស្សជាស្ត្រី និង កុមារ ដែលរៀបចំឡើងដោយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី )LSCW( ក្រោមការសហការដោយ វិទ្យាស្ថាន Overseas Development Institute និងជំនួយបច្ចេកទេសរបស់មូលនីធិអង្គសហប្រជាតិសម្រាប់ស្ត្រី UN WOMEN នៅសណ្ឋាគារ រ៉ាហ្វលឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ។
- លោកប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ និងលោកអនុប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ចំនួន ០២រូប ដឹកនាំដោយឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** បានចុះស្រាវជ្រាវករណីពលករខ្មែររាប់រយនាក់ឆ្លងដែនតាមច្រករបៀងដោយខុសច្បាប់ក្នុងពេលយប់ នៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ (ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង)។

| | |
|---|---|
| | ៧. លេខាធិការដ្ឋាន គ.ខ.ប.ជ៖<br>❖ ការងាររដ្ឋបាល មានដូចខាងក្រោម:<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (១១ច្បាប់) លិខិតចូល (១៣ច្បាប់)។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ (២៨ច្បាប់) លិខិតចូល (១១ច្បាប់)។<br>- បានធ្វើរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ប្រចាំខែ និងត្រីមាសទី៣)។<br>- បានរៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- បានបញ្ជូនរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទៅកាន់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។<br>- បានចងក្រង ព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដាក់ចូលក្នុងបណ្ណាសារវិតី និងគ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- បានស្រាវជ្រាវព័ត៌មានពាក់ព័ន្ធ នឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មាន ដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>- បានស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី និងរៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ នៅរៀងរាល់កិច្ចប្រជុំ។<br>- បានបូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែ ឆ្នាំ២០១៨ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | បានចាត់មន្ត្រីចូលរួមសិក្ខាសាលា ០៤លើក៖<br>- ស្តីពី ការពិនិត្យសេចក្តីព្រាងគោលការណ៍ណែនាំនីតិវិធីអនុវត្តបែបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍។<br>- ស្តីពី ការជំរុញការអនុវត្តអនុក្រឹត្យលេខ១០៨ ស្តីពីការកំណត់អត្រា និងបែបបទជ្រើសរើសជនពិការចូលបម្រើការងារ។<br>- ស្តីពី ការបូកសរុបលទ្ធផលប្រចាំឆ្នាំនៃការអនុវត្តគោលនយោបាយស្តារលទ្ធកម្ម។<br>- ស្តីពី ការចែករំលែកព័ត៌មានថ្នាក់តំបន់ ស្តីពីការអនុវត្តល្អៗក្នុងការផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនទេសន្ត-ប្រវេសន៍ងាយរងគ្រោះ។ |
| អគ្គនាយកដ្ឋានអន្តោប្រវេសន៍ | - បានអនុញ្ញាតឲ្យលោក Glen McEWen ប្រធានគ្រប់គ្រងតំបន់អាស៊ី និងសហការី នៃនគរបាលសហព័ន្ធអូស្ត្រាលី ដើម្បីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។<br>- បានអនុញ្ញាតឲ្យ Fohn D.Wikson ជាសេនានុត្ត័នច្បាប់ និងសហការី  នៃការិយាល័យស៊ើបអង្កេតសហព័ន្ធសហរដ្ឋអាមេរិក ម្បីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។ |

| លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៦លើក អ្នកចូលរួមសរុបចំនួន ២៩៤នាក់ (ស្រី ១៧២នាក់) | |
|---|---|
| ខេត្តកណ្តាល | - ក្រុមការងារថ្នាក់ក្រុង-ស្រុកទាំង១១ បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន ០៧លើក អ្នកចូលរួមចំនួន ១៩៤នាក់ ស្រី ៩២នាក់។<br>- ក្រុមការងារស្រុកស្អាងបានប្រជុំពង្រឹងសមត្ថភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០១លើក។ |
| ខេត្តព្រៃវែង | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមប្រជុំពិភាក្សាបូកសរុបរបាយការណ៍១០ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- បានរៀបចំកិច្ចប្រជុំប្រចាំខែនៅគណៈកម្មាធិការពិគ្រោះយោបល់ និងលេខាធិការដ្ឋានខេត្តដើម្បីផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធ និងជំនាញប្រឆាំងការជួញដូរមនុស្សដល់គណៈអភិបាលស្រុក និងក្រុមប្រឹក្សាឃុំ។ |
| ខេត្តសៀមរាប | - លេខាធិការដ្ឋាន (គ.ខ.ប.ជ) បានរៀបដឹកនាំកិច្ចប្រជុំប្រចាំខែតុលា ឆ្នាំ២០១៨ អ្នកចូលរួមចំនួន ៤៦នាក់ ស្រី ២១នាក់។<br>- លេខាធិការដ្ឋាន (គ.ខ.ប.ជ) បានរៀបដឹកនាំកិច្ចប្រជុំប្រចាំខែវិច្ឆិកា ឆ្នាំ២០១៨ អ្នកចូលរួមចំនួន ៥១នាក់ ស្រី ២៩នាក់។ |
| ខេត្តតាកែវ | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមប្រជុំពិភាក្សាបូកសរុបរបាយការណ៍១០ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ |
| ខេត្តក្រចេះ | - លេខាធិការដ្ឋាន (គ.ខ.ប.ជ) បានរៀបចំកិច្ចប្រជុំស្តីពីការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែវិច្ឆិកា អ្នកចូលរួម ២៨នាក់ ស្រី ១៩នាក់។ |
| ខេត្តកែប | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមប្រជុំពិភាក្សាបូកសរុបរបាយការណ៍១០ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ |
| ខេត្តកោះកុង | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមប្រជុំពិភាក្សាបូកសរុបរបាយការណ៍១០ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ |
| ខេត្តកំពង់ឆ្នាំង | - លេខាធិការដ្ឋាន (គ.ខ.ប.ជ) បានរៀបចំកិច្ចប្រជុំប្រចាំខែ ជាមួយក្រុមការងារទាំង៧ និងសមាសភាពមកពីក្រុង ស្រុក ទាំង០៨ ទូទាំងខេត្ត។ |

| | |
|---|---|
| ខេត្តកំពង់ធំ | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមប្រជុំពិភាក្សាបូកសរុបរបាយការណ៍១០ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ |
| ខេត្តកំពង់ស្ពឺ | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមប្រជុំពិភាក្សាបូកសរុបរបាយការណ៍១០ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ |
| ខេត្តព្រះសីហនុ | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមប្រជុំពិភាក្សាបូកសរុបរបាយការណ៍១០ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ |
| ខេត្តកំពង់ចាម | - គណៈកម្មាធិការស្រុកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានរៀបចំប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។ |
| ខេត្តបន្ទាយមានជ័យ | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូលសរុបលទ្ធផលការងារប្រចាំខែ ០១លើក អ្នកចូលរួមចំនួន ២៥នាក់ ស្រី ១១នាក់។ |
| ខេត្តប៉ៃលិន | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមប្រជុំពិភាក្សាបូកសរុបរបាយការណ៍១០ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ |